**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងសុខាភិបាល

# សេចក្តីជូនព័ត៌មានរបស់ក្រសួងសុខាភិបាល
# ស្តីពី
# ការផ្ទុះឡើងនៃជំងឺឈីគគន់ហ្គុន់យ៉ា ( Chikunngunya ) នៅខេត្តបន្ទាយមានជ័យ
# ថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២០

ក្រសួងសុខាភិបាលនៃព្រះរាជាណាចក្រកម្ពុជា សូមជម្រាបជូនសាធារណៈជនទាំងអស់ឱ្យបានជ្រាបថា ក្នុងពេលថ្មីៗនេះ មានការកើតចេញនូវជំងឺឈីគគន់ហ្គុន់យ៉ា (Chikunngunya) ដែលហៅកាត់ថា ឈីក (CHIK) នៅក្នុងភូមិមួយចំនួននៃសង្កាត់ប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ។ ចាប់តាំងពីថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០២០ រហូតដល់ថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០២០ ប្រជាពលរដ្ឋនៅភូមិក្បាលកោះ ភូមិអូរជ្រៅ ភូមិប៉ោយប៉ែត ភូមិព្រៃគប់ ភូមិអូរនាង និងភូមិអូរឫស្សី នៃសង្កាត់ប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ មានចេញរោគសញ្ញា គ្រុនក្តៅ ៣៨អង្សាសេ កន្ទួលក្រហមលើស្បែក និងឈឺសន្លាក់ដៃជើង ។

ក្រុមឆ្លើយតបបន្ទាន់របស់ក្រសួងសុខាភិបាល មន្ទីរសុខាភិបាលខេត្តបន្ទាយមានជ័យ កម្មវិធីជាតិផ្តល់ថ្នាំបង្ការ ក្រុមគ្រូពេទ្យមណ្ឌលសុខភាព និងមន្ទីរពេទ្យប៉ោយប៉ែត សហការជាមួយអាជ្ញាធរមូលដ្ឋាន បានចុះស្រាវជ្រាវអង្កេតទៅដល់ភូមិទាំង ០៦ខាងលើនេះ និងផ្ទះប្រជាពលរដ្ឋដែលមានបញ្ហា ដើម្បីពិនិត្យស្ថានភាពសុខភាពជាក់ស្តែង បានចំនួន ១៦៨នាក់ (ស្រី ៩៥នាក់) និងបានបញ្ជូនបុគ្គលដែលមានបញ្ហាសុខភាព មកពិនិត្យ និងសម្រាកព្យាបាលនៅមណ្ឌលសុខភាពប៉ោយប៉ែត១ និងមន្ទីរពេទ្យបង្អែកប៉ោយប៉ែត មានចំនួន ៣២នាក់ (ស្រី២៣នាក់) ប៉ុន្តែបច្ចុប្បន្ន ស្ថានភាពសុខភាពរបស់ពួកគាត់ មានសភាពបានធូរស្បើយហើយ។ ស្របតាមលក្ខណៈបច្ចេកទេស ក្រុមការងារ ក៏បានប្រមូលសំណាកវត្ថុវិភាគឈាម ចំនួន ២២នាក់ (ស្រី ១២នាក់) ដើម្បីធ្វើតេស្តវិភាគរកមើលវីរុសគ្រុនឈីក (CHIK ) និងមើលរកវីរុសកញ្រ្ជិល-ស្អូច (Measles - Rubella) ចំនួន ៦០នាក់ (ស្រី ៣៧នាក់) និងយកសំណាកសម្រាប់ធ្វើតេស្តរកវីរុសកូវីដ-១៩ ចំនួន២២នាក់ (ស្រី១១នាក់) ផងដែរ។ សំណាកទាំងអស់នេះ ត្រូវបានបញ្ជូនទៅមន្ទីរពិសោធន៍វិទ្យាស្ថានប៉ាស្ទ័រកម្ពុជា ដែលលទ្ធផលជាបឋមចេញនៅយប់ថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០២០ បានបង្ហាញថា ជាករណីជំងឺគ្រុនឈីក។

ជំងឺគ្រុនឈីក (CHIK) កើតឡើងដំបូងបំផុតនៅឆ្នាំ១៩៥៣ នៅទ្វីបអាហ្វ្រិក និងធ្លាប់បានរកឃើញដំបូងនៅកម្ពុជាដោយវិទ្យាស្ថានប៉ាស្ទ័រកម្ពុជា នៅឆ្នាំ១៩៦១ និងនៅឆ្នាំ ២០១១ ក៏មានការបញ្ជាក់ពីករណីជំងឺនេះ នៅខេត្តបាត់ដំបង សៀមរាប និងព្រះវិហារដែរ ហើយជំងឺគ្រុនឈីក ធ្លាប់មានអត្រាឆ្លងរោគខ្ពស់រហូតដល់ ៦០-៧០% ក្នុងប្រទេសកម្ពុជានាទសវត្សរ៍ទី៦០ ហើយមានការរាតត្បាតខ្លាំងផងដែរនៅក្នុងឆ្នាំ២០១១-២០១២ នៅខេត្តព្រះវិហារ ខេត្តកំពង់ស្ពឺ រាជធានីភ្នំពេញ ខេត្តកំពង់ចាម ខេត្តតាកែវ ខេត្តរតនគិរី ខេត្តស្ទឹងត្រែង ខេត្តកំពង់ធំ ខេត្ត



ទីស្តីការក្រសួងសុខាភិបាល ផ្លូវលេខ ៨០ វិថីសម្តេចប៉ែន នុត (២៨៩) ភ្នំពេញ ទូរស័ព្ទ-ទូរសារ: (៨៥៥-២៣) ៨៨៥ ៩៧០ / ៨៨៤ ៩០៩

កណ្តាល និងខេត្តកំពត។ បច្ចុប្បន្ននេះ ក្រៅអំពីការទប់ការស្កាត់នូវការចម្លងវីរុសកូវីដ-១៩ នៅក្នុងប្រទេសកម្ពុជា ការលេចឡើងនៅជំងឺគ្រុនឈីក សារជាថ្មីឡើងវិញនៅខេត្តបន្ទាយមានជ័យនេះ អាចជាបញ្ហាសុខភាពសាធារណៈមួយទៀត ដែលប្រឈមទៅនិងហានិភ័យអាចឲ្យមានការឆ្លងរាលដាលពីបុគ្គលម្នាក់ទៅបុគ្គលម្នាក់ ពីគ្រួសារមួយទៅគ្រួសារមួយ ពីភូមិមួយទៅភូមិមួយ ពីឃុំមួយទៅឃុំមួយទៀតជាដើម តាមរយៈមូសខ្លាញីខាំ ដែលចល័តពីកន្លែងមួយទៅកន្លែងមួយតាមមធ្យោបាយធ្វើដំណើរផ្សេងៗ និងតាមទីកន្លែងដែលមិនមានអនាម័យបរិដ្ឋានស្អាត និងទីកន្លែងដែលបង្កឲ្យមានជម្រកមូសខ្លាច្រើន ជាដើម។ ជំងឺនេះអាចកើតលើមនុស្សគ្រប់វ័យ ទាំងក្មេង និងចាស់។

ជំងឺគ្រុនឈីក (CHIK) គឺជាជំងឺបង្កឡើងដោយវីរុសឈីក ហើយចម្លងតាមរយៈមូសខ្លាញីខាំ ជាពិសេសខាំនៅពេលថ្ងៃ។ ភ្នាក់ងារចម្លង គឺសត្វមូសប្រភេទក្រុមអាអេដេស (Aedes Aegypti and Aedes Albopictus) ដែលជាភ្នាក់ងារចម្លងជំងឺគ្រុនឈាមផងដែរ។ រោគសញ្ញារួមមាន៖ គ្រុនក្តៅស្រួចស្រាវលើសពី ៣៨អង្សារសេ ឈឺសន្លាក់ ឈឺសាច់ដុំ ឈឺក្បាល ក្អួតចង្អោរ អស់កំលាំង មានស្នាមកន្ទួលក្រហមលើខ្លួន និងកន្ទួលក្រហមលើស្បែកដៃ។ ជាទូទៅ ជំងឺគ្រុនឈីក មិនបណ្តាលឱ្យអ្នកជំងឺស្លាប់បាត់បង់ជីវិតទេ ស្ទើរតែគ្រប់អ្នកជំងឺទាំងអស់បានជាសះស្បើយឡើងវិញក្នុងរយៈពេលក្នុងមួយសប្តាហ៍ ឬអាចមានរយៈពេលយូរដល់រាប់អាទិត្យក្នុងករណីខ្លះៗដែរ ជាពិសេសជំងឺនេះ អាចធ្វើឲ្យអ្នកជំងឺមានអាការៈឈឺសន្លាក់ដៃជើងក្នុងរយៈពេលយូរ (ដល់ឆ្នាំ) ក៏មានដែរ ហើយជំងឺនេះ អាចបណ្តាលឲ្យស្លាប់បាត់បង់ជីវិតបាន នៅក្នុងករណីដែលអ្នកជំងឺកើតមានជំងឺនេះរួមផ្សំគ្នាជាមួយជំងឺផ្សេងៗ ដូចជាជំងឺគ្រុនចាញ់ ជំងឺគ្រុនឈាម ជំងឺរលាកស្រោមខួរជាដើម ព្រោះជំងឺរួមផ្សំទាំងនេះអាចបណ្តាលឱ្យអ្នកជំងឺស្លាប់បាន។ ទោះបីជាជំងឺគ្រុនឈីក មានហានិភ័យបណ្តាលឱ្យស្លាប់ក្នុងកម្រិតទាបក៏ពិតមែន តែវានាំឱ្យប៉ះពាល់សុខភាព ខាតបង់ពេលវេលារៀនសូត្រ ពេលវេលាធ្វើការរកស៊ីទទួលទានចិញ្ចឹមជីវិតប្រចាំថ្ងៃ ជាពិសេសអ្នកមានវ័យចំណាស់ចាប់ពីអាយុ៥០ឆ្នាំឡើង ពួកគាត់អាចឈឺសន្លាក់ឆ្អឹងយូរ ដែលប៉ះពាល់ដល់សុខភាពបុគ្គល សេដ្ឋកិច្ចគ្រួសារ និងសង្គមផងដែរ។ សូមបងប្អូនប្រជាពលរដ្ឋទាំងអស់ ចូលរួមការពារការចម្លងជំងឺគ្រុនឈីកនេះ នៅក្នុងមូលដ្ឋានរបស់ខ្លួន ទៅតាមការណែនាំ និងប្រសាសន៍ដ៏មានសារសំខាន់ មានដូចខាងក្រោមនេះ ៖

**ឯកឧត្តមសាស្ត្រាចារ្យ ម៉ម ប៊ុនហេង រដ្ឋមន្ត្រីក្រសួងសុខាភិបាល** មានប្រសាសន៍ថា ៖ " *ការទប់ស្កាត់ និងការពារជំងឺឈីក (CHIK) គឺវាដូចគ្នាទៅនិងជំងឺគ្រុនឈាមដែរ ដោយផ្អែកទៅលើការការពារកុំឱ្យមូសខ្លាញីខាំ តាមរយៈការកំចាត់វត្ថុដក់ទឹក ដែលជាជម្រកនៃការកកើតសត្វមូសនេះ។ ខ្ញុំសូមជំរុញឱ្យថ្នាក់ដឹកនាំមូលដ្ឋានគ្រប់ថ្នាក់ទាំងអស់ ចលនាប្រជាជននៅក្នុងសហគមន៍ ក្នុងការកំចាត់ជម្រកមូសខ្លា ដែលនាំឱ្យកកើតជង្គូវទឹក និងមានមូសបង្ករជំងឺ ស្លៀកពាក់ខោអាវវែង និងសំរាន្តក្នុងមុង។ ពេលមានជំងឺដែលមានរោគសញ្ញាដូចខាងលើ សូមអញ្ជើញទៅមណ្ឌលសុខភាព ឬមន្ទីរពេទ្យបង្អែកដែលនៅជិតលោកអ្នកជាទីបំផុត ដើម្បីពិនិត្យពិគ្រោះជំងឺ និងទទួលបានការព្យាបាលបានទាន់ពេលវេលា និងរាល់ករណីសង្ស័យគ្រុនឈីកក្នុងមួយសប្តាហ៍ដំបូងនៃជំងឺនេះ ត្រូវសម្រាកនៅក្នុងមុង ឬក្នុងបន្ទប់មានសំណាញ់ការពារ ដើម្បីការពារកុំឱ្យមូសខាំចម្លងបន្តទៅសមាជិកគ្រួសារ ឬអ្នកជិតខាង*។ លើសពីនេះ សូមបងប្អូនប្រជាពលរដ្ឋទាំងអស់ចូលរួមអនុវត្តនូវវិធានការណ៍ដូចខាងក្រោម ដើម្បីការពារខ្លួនយើងក្រុមគ្រួសារយើង ជៀសផុតពីការឆ្លងជំងឺឈីក និងជំងឺគ្រុនឈាម និងហ្ស៊ីកា ផងដែរ ៖



ទីស្តីការក្រសួងសុខាភិបាល ផ្លូវលេខ ៨០ វិថីសម្ដេចប៉ែន នុត (២៨៩) ភ្នំពេញ ទូរស័ព្ទ-ទូរសារ: (៨៥៥-២៣) [illegible] / ៨៨០ ៤០៩

- បំបាត់ជម្រកមូសខ្លា ដោយធ្វើអនាម័យសំអាតជុំវិញផ្ទះ លុបបំបាត់គុម្ពោតស៊ុបទ្រុបនៅជុំវិញផ្ទះ ការពារកុំឲ្យមានទឹកដក់នៅជុំវិញផ្ទះ លុបបំបាត់ផ្តុក សំបកកំប៉ុង សំបកកង់ឡាន ត្រឡោកដូង ធុងទឹក ជើងផ្កា និងប្រើអាបែតដាក់ក្នុងពាង ឬ អាងស្តុកទឹក ជារៀងរាល់អាទិត្យ។
- ស្លៀកពាក់ខោជើងវែង អាវដៃវែង និងស្រោមជើង ធ្វើយ៉ាងណាគ្របដណ្តប់ភាគច្រើននៃរាងកាយឲ្យជិត (សម្លៀកបំពាក់គួរតែមានពណ៌ភ្លឺ កុំខ្មៅឬងងឹត)
- ប្រើថ្នាំបាញ់ (spray) ឬលាប (repellent) កុំឲ្យមូសមកជិត ព្រោះថ្នាំនេះ ស្ត្រីមានផ្ទៃពោះអាចប្រើបាន ដោយមានសុវត្ថិភាព មិនមានផលប៉ះពាល់ទេ
- សំរានក្នុងមុង រាល់ពេលសំរាន្តនៅពេលយប់ និងថ្ងៃ ព្រមទាំងបើកបង្អួច ទ្វារ ឲ្យធំ ដើម្បីឲ្យពន្លឺថ្ងៃ និងមានខ្យល់ចេញចូលបានល្អ

ក្រសួងសុខាភិបាល និងបន្តធ្វើការជូនដំណឹងដល់សាធារណជន អំពីការវិវត្តន៍នៃបញ្ហាសុខភាពតាមទំព័រហ្វេសប៊ុក និងគេហទំព័ររបស់ក្រសួងសុខាភិបាល www.cdcmoh.gov.kh ដែលគេហទំព័រនេះមានសម្ភារអប់រំសុខភាព ដែលអាចទាញយកមកមើល និងប្រើប្រាស់បាន។ សំរាប់ព័ត៌មានបន្ថែម សូមទាក់ទងលេខទូរស័ព្ទទាន់ហេតុការណ៍ ក្រសួងសុខាភិបាល លេខ ១១៥ ដោយឥតគិតថ្លៃ ឬទំនាក់ទំនងក្រសួងសុខាភិបាល តាមលេខទូរស័ព្ទ៖ ០១២ ៨២៥ ៤២៤ ឬ ០១២ ៤៨៨ ៩៨១ ឬ ០១២ ៨៣៦ ៨៦៨។

ថ្ងៃព្រហស្បតិ៍ ០៣កើត ខែស្រាពណ៍ ឆ្នាំជូត ទោស័ក ពស ២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២០